ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៦២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារ ដើម្បីពិភាក្សាជាមួយ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អំពីការប្រមូលពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនបានប្រើប្រាស់

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច :

**ប្រការ១ :** បង្កើតក្រុមការងារ ដើម្បីពិភាក្សាជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អំពីការប្រមូលពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលរួមមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ចាង់ ផូនណារ៉ុត** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក **តាំង លាងទ័ណ្ឌ** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | អនុប្រធាន |
| ៣- លោក **ឈីវ ប៊ុនថៃ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |
| ៤- លោក **ស៊ុម អៀង** | ប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ៥- លោក **ប៉ែន វុត្ថា** | អនុប្រធានទី១ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៦- លោក **ចាន់ ស៊ុំ** | អនុប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ៧- លោក **កែវ នាន់** | ប្រធានសាខាពន្ធដាររាជធានីភ្នំពេញ | សមាជិក |
| ៨- លោក **ទី សុមាត** | ប្រធានសាខាពន្ធដារខេត្តសៀមរាប | សមាជិក |
| ៩- លោក **ទាវ សាវឿន** | ប្រធានសាខាពន្ធដារខេត្តកណ្ដាល | សមាជិក |
| ១០- លោក **អោម ចន** | ប្រធានសាខាពន្ធដារខេត្តស្វាយរៀង | សមាជិក |
| ១១- លោក **ថា ពិសិដ្ឋ** | ប្រធានសាខាពន្ធដារខេត្តកំពត | សមាជិក |

**ប្រការ២ :** ក្រុមការងារនេះ មានភារកិច្ចរៀបចំឯកសារមួយចំនួនទាក់ទងនឹងការប្រមូលពន្ធប្រថាប់ត្រា លើការផ្ទេរអចលនវត្ថុ សំរាប់ការប្រជុំពិភាក្សាជាមួយមន្ត្រីជំនាញនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដូចតទៅ :

- វិធានការដើម្បីកំណត់តំលៃនៃការទិញ-លក់អចលនវត្ថុ ដែលជាមូលដ្ឋាននៃការគិតពន្ធឱ្យបានខិតជិតទៅនឹងតំលៃពិតរបស់អចលនវត្ថុ
- នីតិវិធីនៃការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធ ចំពោះអចលនវត្ថុមិនទាន់ចុះបញ្ជី
- លទ្ធភាពបញ្ចុះអត្រាពន្ធប្រថាប់ត្រា
- យន្តការនៃការប្រមូលពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- អំពីខ្ទង់ចំណូលពីពន្ធប្រថាប់ត្រាក្នុងថវិកាជាតិ
- កំរិតនៃការលើកទឹកចិត្តសំរាប់ផ្តល់ជូនរដ្ឋបាលសុរិយោដីផ្នែកពន្ធដារ និងរដ្ឋអំណាចឃុំ-សង្កាត់ ក្នុងការប្រមូលពន្ធប្រថាប់ត្រា

**ប្រការ៣ :** ក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងត្រូវធ្វើរបាយការណ៍ជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាប្រចាំអំពីលទ្ធផលដែលខ្លួនសំរេចបានក្នុងការបំពេញភារកិច្ចខាងលើ ហើយជាយថាហេតុសុំការណែនាំ និងវិធានការសំរាប់កិច្ចការនេះឱ្យមានប្រសិទ្ធិភាព ។

**ប្រការ៤ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និង ឯកឧត្តម អស់លោក ដែលមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៥

**គាត ឈន់**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងរៀបចំដែនដីនគរូបនីកម្ម និងសំណង់
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ